**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌ លេខៈ **១៦៣៧ អក**

ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

សាលក្រមលេខៈ **០៧៦ (ណ)**

ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកណ្តាល

-បានបើកសវនាការជំនុំជម្រះសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ ដោយមានសមាសភាពដូចតទៅ:

**សមាសភាពជំនុំជំរះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី ចៅក្រុមប្រឹក្សា

លោក ចៅក្រុមប្រឹក្សា

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**មេធាវី**

មេធាវី[redacted]

និងមេធាវី [redacted] មេធាវីការពារជនជាប់ចោទឈ្មោះ[redacted]សុខនី និងឈ្មោះ[redacted]សុភា

**ដើម្បីជំនុំជំរះ** សំណុំរឿងព្រហ្មទណ្ឌលេខៈ **១៦៣៧ អក** ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ ដែលមានជនជាប់ចោទៈ

១-ឈ្មោះ [redacted] សុខនី ហៅ ប៊ុជ ភេទប្រុស អាយុ ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted]សា (រស់) ម្តាយឈ្មោះ [redacted]ង៉ន (រស់) នៅលីវ ជានីតិជន ទោសពីមុនៈ គ្មាន (ឃុំខ្លួនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០)។

២-ឈ្មោះ [redacted]សុភា ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ[redacted]ភក្តី (រស់) ម្តាយឈ្មោះ [redacted] គឹមហឿន (រស់) ប្រពន្ធឈ្មោះ[redacted]ម៉ី (រស់) ជានីតិជន ទោសពីមុនៈ គ្មាន (ឃុំខ្លួនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០)។

ត្រូវជាប់ចោទពីបទៈ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ បញ្ញត្តិផ្ទន្ទាទោសតាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ។

ភវ



Scanned with CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឈ្មោះ [redacted] សុភ័ក្ត ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិឫស្សី ឃុំព្រះនិព្វាន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជានីតិជន។

**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ៖ **១៧៩៤** ដកសព ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ របស់តំណាង អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

**បានឃើញ** ដីកាដំណោះស្រាយលេខ៖ **១៩០៧** ដកដស ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកណ្តាល ។

**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ៖ ២២៨១ ដកចត ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តកណ្តាល ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ២១ និង១០នាទី ខណៈដែលជនរងគ្រោះឈ្មោះ [redacted] **សុភ័ក្ត** កំពុងបើកម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីមស៊េរីឆ្នាំ២០១៩ ពាក់ស្លាកលេខ បាត់ដំបង ១AH-១៣០១ ដល់ចំណុចកើតហេតុ ស្ថិតនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ស្រាប់តែមានជនត្រូវចោទឈ្មោះ [redacted] **សុខនី** ,ឈ្មោះ [redacted] **សុភា** និងឈ្មោះ **សំអន** ជិះម៉ូតូមួយគ្រឿងម៉ាក ស្កុបពី ពណ៌ខ្មៅ ពាក់ស្លាកលេខ តាកែវ ១V-២៥២៧ ធ្វើសកម្មភាពធាក់ម៉ូតូជនរងគ្រោះឈ្មោះ [redacted] **សុភ័ក្ត** ដែលកំពុងបើកបរបណ្តាលឱ្យដួល ហើយជនត្រូវចោទឈ្មោះ **សំអន** បានស្ទុះទៅលើកម៉ូតូជនរងគ្រោះជិះគេចខ្លួនបាត់ ចំណែកជនត្រូវចោទឈ្មោះ [redacted] **សុខនី** និងឈ្មោះ [redacted] **សុភា**បានបើកម៉ូតូគេចខ្លួនផងដែរ តែត្រូវបានប្រជាពលរដ្ឋ និងសមត្ថកិច្ចស្ទាក់ចាប់បាន និងដកហូតបានវត្ថុតាងជា ម៉ូតូ១គ្រឿងម៉ាក ស្កុបពី ពណ៌ខ្មៅ ពាក់ស្លាកលេខ តាកែវ ១V-២៥២៧ បញ្ជូនទៅអធិការដ្ឋានស្រុកកណ្តាលស្ទឹង ដើម្បីធ្វើការសាកសួរ និងកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តកណ្តាល ដើម្បីចាត់ការតាមនីតិវិធី។

## នារពលសទនាភារ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានរបាយការណ៍របស់នគរបាលយុត្តិធម៌

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់។

## សាលាដំបូងខេត្តកណ្តាល
## យល់ឃើញថា

### ក.អំពីពិរុទ្ធភាព៖

១-តាមដីកាដំណោះស្រាយលេខ **១៩០៧** ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សុខនី និងឈ្មោះ [redacted] សុខភា មកតុលាការដើម្បីជម្រះពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ បញ្ញត្តិផ្តន្ទាទោសតាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

២-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខនី បានឆ្លើយថាៈ កាលពីថ្ងៃ២៨ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ០៦ល្ងាច ឈ្មោះ [redacted] សុភា ជាមិត្តភ័ក្រ្ត បានហៅខ្លួនទៅជាមួយដោយប្រាប់ថាទៅនោះមួយភ្លែត ខ្លួនបានជិះម៉ូតូស្កុបពី ពណ៌ខ្មៅ ទៅជាមួយ ពេលជិះបានបន្តិច ក៏បានឃើញបុរសម្នាក់មិនស្គាល់ឈ្មោះនៅតាមផ្លូវ ហើយបុរសម្នាក់នោះបានឡើងជិះម៉ូតូជាមួយរួចចូលហូបអី ហើយឈ្មោះ [redacted] សុភា បានហៅបុរសម្នាក់នោះថា ឈ្មោះ សំអន បន្ទាប់មកឈ្មោះ សំអន បានឱ្យឈ្មោះ [redacted] សុភា ជូនទៅភ្នំពេញ ឮដូច្នេះបានប្រកែកព្រោះឪពុកចាំហូបបាយ តែឈ្មោះ [redacted] សុភា បានអង្វរឱ្យទៅជាមួយពេលត្រឡប់មកវិញបានជាគ្នា ខ្លួនក៏ព្រម ដោយតាមផ្លូវឃើញបុរសម្នាក់ជិះម៉ូតូឌ្រីមសង់ ពេលនោះឈ្មោះ សំអន បានប្រាប់ឱ្យឈ្មោះ [redacted] សុភា ធាក់ម៉ូតូគេឱ្យដួល តែឈ្មោះ [redacted] សុភា ប្រកែកមិនព្រមធ្វើតាម ក្រោយមកឮឈ្មោះ សំអន និយាយរំលឹកពីរឿងលុយ តែខ្លួនមិនដឹងរឿងលុយអីទេ ហើយឈ្មោះ [redacted] សុភា ក៏ព្រម តែខ្លួនបានកេះឈ្មោះ [redacted] សុភា ថាខ្លួនមិនហ៊ានទេ តែឈ្មោះនេះមិនស្តាប់ហើយជិះទៅគៀកម៉ូតូជនរងគ្រោះ ហើយបានធាក់ម៉ូតូផ្តួល ហើយខ្លួនឃើញឈ្មោះ សំអន លោតចុះពីលើម៉ូតូដែលខ្លួនកំពុងជិះទៅលើកម៉ូតូជនរងគ្រោះជិះគេចចេញទៅ ចំណែកម៉ូតូឈ្មោះ [redacted] សុភា ដែលឌុបខ្លួនបានជិះរត់ដែរ បានឆ្ងាយបន្តិចក៏ឃើញមានសមត្ថកិច្ច និងប្រជាការពារព័ទ្ធចាប់ ឈ្មោះ [redacted] សុភា ភ័យពេកក៏បានផ្តួលម៉ូតូរត់ ហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនមិនធ្លាប់ធ្វើសកម្មភាពប្លន់ម៉ូតូគេទេ ហើយខ្លួនក៏មិនធ្លាប់ប្រើប្រាស់ថ្នាំញៀនដែរ ។

៣-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សុភា បានឆ្លើយថាៈ កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ខ្លួនបានជិះម៉ូតូស្កុបពី ចេញពីខេត្តតាកែវ ដោយជិះគ្នា ៣នាក់ មានឈ្មោះ [redacted] សុខនី ,ឈ្មោះ សំអន និងខ្លួន ដោយជូនឈ្មោះ សំអន ទៅភ្នំពេញវិញ ពេលជិះដល់ម្តុំកំពង់ទួល ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ម៉ោងប្រហែល ៩យប់ បានជួបជាមួយជនរងគ្រោះកំពុងជិះម៉ូតូឌ្រីមសង់ ពណ៌ខ្មៅ ជិះម្នាក់ឯង ពេលនោះឈ្មោះ សំអន បានឱ្យខ្លួនជិះចូលគៀក រួចឈ្មោះ សំអន បានឱ្យខ្លួនធាក់ម៉ូតូជនរងគ្រោះឱ្យដួល បន្ទាប់មកឈ្មោះ សំអន បានហក់ចុះពីលើម៉ូតូទៅលើកម៉ូតូរបស់ជនរងគ្រោះជិះគេចទៅម្នាក់ឯងបាត់ទៅ នៅសល់ តែខ្លួន និងឈ្មោះ [redacted] សុខនី ជិះគេចដែរ ក៏ត្រូវបានសមត្ថកិច្ចព័ទ្ធចាប់បាននាំពួកខ្លួនមកអធិការដ្ឋានស្រុកកណ្តាលស្ទឹងតែម្តង។ ខ្លួនធ្លាប់ធ្វើសកម្មភាពប្លន់យកម៉ូតូគេចំនួន ២លើក ដោយលើកទី១ ធ្វើសកម្មភាពជាមួយឈ្មោះ សំអន ឈ្មោះ កាយ ឈ្មោះ គ្រេន និងរូបខ្លួន បានធាក់ប្លន់យកម៉ូតូម៉ាកឌ្រីមសង់០១៨ ពណ៌ខ្មៅ ពីជនរងគ្រោះបានសម្រេច ហើយឈ្មោះ សំអន បានយកម៉ូតូទៅលក់ រួចឈ្មោះនេះបានឱ្យប្រាក់មកខ្លួនចំនួន ៨០ដុល្លាអាមេរិច ។ ចំពោះឈ្មោះ [redacted] សុខនី មិនធ្លាប់ធ្វើសកម្មភាពជាមួយខ្លួននោះទេ នៅថ្ងៃកើតហេតុខ្លួនហៅឱ្យមកជួយជូនឈ្មោះ សំអន មកភ្នំពេញពេលត្រឡប់ទៅតាកែវវិញបានជាគ្នា ខ្លួនមិនធ្លាប់ប្រើប្រាស់គ្រឿងញៀនទេ ។

៤-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុភ័ក្ត បានឆ្លើយថាៈ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ម៉ោង ៤ និង១០នាទីល្ងាច ខ្លួនបានជិះម៉ូតូខ្លួនម៉ាក ហុងដា សេ១២៥ ពណ៌ខ្មៅ សេរីឆ្នាំ២០១៩ ពាក់ស្លាកលេខបាត់ដំបង ១AH-១៣០១ ចេញពីកន្លែងធ្វើការ ទៅម្តុំផ្សារទួលពង្រ នៅវេលាម៉ោងប្រហែល ៩យប់ ក៏ជិះត្រលប់ទៅផ្ទះនៅភូមិឫស្សី ឃុំព្រះនិព្វាន្ត ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ស្រាប់តែមានចោរបីនាក់ បានជិះម៉ូតូមួយគ្រឿងម៉ាកស្កុបពី ពណ៌ខ្មៅ រួចធាក់ខ្លួនពីក្រោយបណ្តាលឱ្យដួលទៅនឹងចិញ្ចើមផ្លូវ ហើយម្នាក់ដែលធាក់ខ្លួន បានយកដំបងវាយខ្លួនថែមទៀត តែខ្លួនគេចទាន់ ហើយស្រែកឱ្យគេជួយ ពេលនោះមានមនុស្សប្រុសពីរនាក់ជិះតាមចោរនោះ។

៥-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ៖ ឆ្លងកាត់តាមអង្គសវនាការនេះ កូនក្តីរបស់ខ្ញុំបាទបានឆ្លើយសារភាពនូវអំពើរបស់ខ្លួនពិតប្រាកដមែន ព្រោះនៅពេលធ្វើសកម្មភាពធក់ម៉ូតូគេនោះ គឺឈ្មោះ សំអន ដែលជិះម៉ូតូជាមួយគ្នាបានបញ្ជាឱ្យកូនក្តី របស់ខ្ញុំឈ្មោះ [redacted] សុភា ជាអ្នកធាក់ម៉ូតូជនរងគ្រោះ ប៉ុន្តែពេលនោះកូនក្តី



Scanned with CamScanner

របស់ខ្ញុំមិនចង់ជាក់ម៉ូតូរបស់ជនរងគ្រោះទេ ដោយសារការបង្ខំរបស់ឈ្មោះ សំអន ជាអ្នកបញ្ជាឱ្យជាក់ម៉ូតូ ព្រោះពេលដើរលេងឈ្មោះ សំអន បានបៅកូនក្តីខ្ញុំឱ្យផឹកស៊ី ហើយអស់លុយ ទើបត្រឡប់ពីតាកែវវិញក៏បានបញ្ជាឱ្យកូនក្តីខ្ញុំឈ្មោះ [redacted] សុភា ជាអ្នកជាក់ម៉ូតូជនរងគ្រោះបណ្តាលឱ្យដួល។ ចំណែកឈ្មោះ [redacted] សុខនី មិនបានធ្វើសកម្មភាពអ្វីទេ គឺគ្រាន់តែជិះម៉ូតូជាមួយឈ្មោះ [redacted] សុភា និងឈ្មោះ សំអន តែប៉ុណ្ណោះ មិនបានធ្វើសកម្មភាពអ្វីទេ។ ហេតុដូច្នេះក្នុងនាមខ្ញុំជាមេធាវីការពារឱ្យឈ្មោះ [redacted]សុភា និងឈ្មោះ [redacted] សុខនី ស្នើសុំដល់លោកប្រធានក្រុមប្រឹក្សា និងលោកស្រីតំណាងអយ្យការមេត្តាជួយបន្ធូរបន្ថយទោសឱ្យកូនក្តីរបស់ខ្ញុំផង។

៦-តាមរបាយការណ៍របស់នគបាលយុត្តិធម៌បានបញ្ជាក់ថា កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ឈ្មោះ [redacted] **សុខនី និងឈ្មោះ** [redacted] **សុភា** ពិតជាបានប្រព្រឹត្តអំពើ ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រើអំពើហិង្សា** ពិតប្រាកដមែន។

៧-តំណាងអយ្យការបានសន្និដ្ឋានថា កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ឈ្មោះ [redacted]**សុខនី** និងឈ្មោះ [redacted] **សុភា** ពិតជាបានប្រព្រឹត្តអំពើ ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រើអំពើហិង្សា** ពិតប្រាកដមែន។ ដូច្នេះតំណាងអយ្យការសូមដំកល់បទចោទនេះនៅដដែល តាមដីកាសន្និដ្ឋានស្ថាពរលេខៈ **១៧៩៤** ដកសព ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ ផ្តន្ទាទោសតាមមាត្រាតាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ជាមូលដ្ឋាន។

៨-តាមចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី របាយការណ៍របស់កងរាជអាវុធហត្ថ និងការសន្និដ្ឋានរបស់តំណាងអយ្យការ មានភាពស៊ីសង្វាក់គ្នា សបញ្ជាក់ឱ្យឃើញថា កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ឈ្មោះ [redacted] **សុខនី** និងឈ្មោះ [redacted] **សុភា** ពិតជាបានប្រព្រឹត្តអំពើ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រើអំពើហិង្សា** ពិតប្រាកដមែន។

៩-អំពើរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិបុគ្គល ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសង្គមបានសង្គមចាត់ទុកជាអំពើល្មើសផ្នែកព្រហ្មទណ្ឌតាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ ។

១០-ជនជាប់ចោទឈ្មោះ [redacted]**សុខនី** ភេទប្រុស អាយុ ១៩ឆ្នាំ ជានីតិជន មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តអំពើខាងលើ។

១១-ជនជាប់ចោទឈ្មោះ [redacted] **សុភា** ភេទប្រុស អាយុ ១៦ឆ្នាំ ជាអនីតិជនក្តី ប៉ុន្តែបុគ្គលិកលក្ខណៈរបស់គេមានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តអំពើខាងលើ។

១២-ជនជាប់ចោទឈ្មោះ [redacted] **សុភា** ភេទប្រុស អាយុ ១៦ឆ្នាំ និង ជាអនីតិជន គប្បីពិចារណាតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

១៣-ជនជាបចោទឈ្មោះ [redacted] **សុខនី** ពិតជាបានរួមដំណើរជាមួយជនជាប់ចោទឈ្មោះ [redacted] **សុភា** និងឈ្មោះ សំអន ពិតប្រាកដមែន តែជនជាប់ចោទឈ្មោះ [redacted] **សុខនី** មិនបានធ្វើសកម្មភាពសកម្មនោះឡើយ គប្បីតុលាការពិចារណាផ្តល់ស្ថានសម្រាលទោសដោយព្យួរទោសមួយផ្នែក។

១៤-មានភស្តុតាង ដាក់បន្ទុកគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពលើឈ្មោះ [redacted] **សុខនី** ភេទប្រុស អាយុ ១៩ឆ្នាំ (ក្នុងឃុំ) និងឈ្មោះ [redacted]**សុភា** ភេទប្រុស អាយុ ១៦ឆ្នាំ (ក្នុងឃុំ) ពីបទ៖ **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ បញ្ញត្តិផ្តន្ទាទោសតាមមាត្រា **៣៥៣** និងមាត្រា **៣៥៧** នៃក្រមព្រហ្មទណ្ឌ។

ៗវ



Scanned with CamScanner

**ខ.វត្ថុចាប់យក ៖** ម៉ូតូចំនួន ០១(មួយ)គ្រឿងម៉ាក Honda Scoopy (មិនប្រក្រតី)ពណ៌ខ្មៅ ពាក់ស្លាកលេខ តាកែវ ១V-២៥២៧ និងកូនសោរម៉ូតូចំនួនមួយគ្រាប់ គប្បីតុលាការតុលាការរឹបអូសជាសម្បត្តិរដ្ឋ ។

**ហេតុដូច្នេះ សាលាដំបូងខេត្តកណ្តាល វិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសលើជនជាប់ចោទ៖

១.១-ឈ្មោះ [redacted] សុខនី ភេទប្រុស អាយុ ១៩ឆ្នាំ(មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ អនុវត្តក្នុងពន្ធនាគាររយៈពេល ០១(មួយ)ឆ្នាំ ០៦(ប្រាំមួយ)ខែ ទោសនៅសល់ត្រូវព្យួរ ។

១.២-ឈ្មោះ [redacted] សុភា ភេទប្រុស អាយុ ១៦ឆ្នាំ(មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០១(មួយ)ឆ្នាំ ០៦(ប្រាំមួយ)ខែ ។

ពីបទ៖ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅភូមិកំពង់ទូល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ បញ្ញត្តិផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២-វត្ថុចាប់យក៖

-ម៉ូតូចំនួន ០១(មួយ)គ្រឿងម៉ាក Honda Scoopy (មិនប្រក្រតី)ពណ៌ខ្មៅ ពាក់ស្លាកលេខ តាកែវ ១V-២៥២៧ និងកូនសោរម៉ូតូចំនួនមួយគ្រាប់ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

-សាលក្រមនេះជំនុំជំរះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សុខនី និងឈ្មោះ [redacted] សុភា តែកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សុភ័ក្ត។

ទុកសិទ្ធិឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ......ខែ......ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

កណ្តាល ថ្ងៃទី......ខែ......ឆ្នាំ២០២១

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]

បានទទួលដំណឹង

ថ្ងៃ......ខែ......ឆ្នាំជូត ឯកស័ក ព.ស ២៥៦៣

កណ្តាល ថ្ងៃទី......ខែ......ឆ្នាំ២០២០

**តំណាងអយ្យការ**

[redacted]